ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៥ លេខ៧៧ ត្រីមាសទី០៤ ឆ្នាំ២០២៥

# រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


| | | |
|---|---|---|
| ៨-១១-២០២៥ | -ព្រះរាជក្រម នស/រកម/១១២៥/០៣៥ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីពីរធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ | ៩៤១១ |
| ៨-១១-២០២៥ | -ព្រះរាជក្រម នស/រកម/១១២៥/០៣៦ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីក្របខ័ណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន | ៩៤១៧ |


### ២~ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ៣១-១០-២០២៥ | -ព្រះរាជក្រឹត្យ នស/រកត/១០២៥/១៤២៨ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **លេខា វិចិត្រ** ជាអគ្គនាយករងនៃនិយ័តករមូលបត្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋ-លេខាធិការ | ៩៤៥៦ |
| ៣១-១០-២០២៥ | -ព្រះរាជក្រឹត្យ នស/រកត/១០២៥/១៤២៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់ថ្នាក់ដឹកនាំ ទីប្រឹក្សា និងមន្ត្រីរាជការ នៃក្រសួងរៀបចំដែនដី នគរូប-នីយកម្ម និងសំណង់ ១៥រូប | ៩៤៥៧ |
| ៣១-១០-២០២៥ | -ព្រះរាជក្រឹត្យ នស/រកត/១០២៥/១៤៣០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសការពារជាតិ ថ្នាក់ មាស ដល់មន្ត្រីនគរបាលជាតិ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ៧៤រូប | ៩៤៥៨ |
| ៣១-១០-២០២៥ | -ព្រះរាជក្រឹត្យ នស/រកត/១០២៥/១៤៣១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់ឧបការី និងមន្ត្រីរាជការ នៃអង្គភាពប្រឆាំងអំពើពុករលួយ ៧រូប | ៩៤៦២ |
| ៣១-១០-២០២៥ | -ព្រះរាជក្រឹត្យ នស/រកត/១០២៥/១៤៣២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពល-ខេមរភូមិន្ទ ៤០រូប | ៩៤៦៣ |
| ៣១-១០-២០២៥ | -ព្រះរាជក្រឹត្យ នស/រកត/១០២៥/១៤៣៣ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **ផាន់ និមិត្ត** ជាជំនួយការសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយក | ៩៤៦៥ |
| ១-១១-២០២៥ | -ព្រះរាជក្រឹត្យ នស/រកត/១១២៥/១៤៤១ ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីរាជការ នៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ២រូប | ៩៤៦៦ |
| ១-១១-២០២៥ | -ព្រះរាជក្រឹត្យ នស/រកត/១១២៥/១៤៤២ ស្តីពី ការតាំងស៊ប់នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងបរិស្ថាន ដល់មន្ត្រីរាជការ ៤រូប | ៩៤៦៧ |
| ១-១១-២០២៥ | -ព្រះរាជក្រឹត្យ នស/រកត/១១២៥/១៤៤៣ ស្តីពី ការតាំងស៊ប់នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅទីស្តីការគណៈរដ្ឋមន្ត្រី ដល់មន្ត្រីរាជការ ១៨រូប | ៩៤៦៩ |
| ១-១១-២០២៥ | -ព្រះរាជក្រឹត្យ នស/រកត/១១២៥/១៤៤៤ ស្តីពី ការដំឡើងថ្នាក់ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល តាមកម្រិតសញ្ញាបត្រ នៅក្រសួងព័ត៌មាន ដល់មន្ត្រីរាជការ ៤រូប | ៩៤៧១ |
| ១-១១-២០២៥ | -ព្រះរាជក្រឹត្យ នស/រកត/១១២៥/១៤៤៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសជាតូបការ ដល់ថ្នាក់ដឹកនាំ នៃក្រសួងអភិវឌ្ឍន៍ជនបទ ៣រូប | ៩៤៧៣ |

១-១១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/១១២៥/១៤៤៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ដល់សប្បុរសជន ៥រូប ៩៤៧៤

១-១១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/១១២៥/១៤៤៧ ស្តីពី ការបញ្ចប់មុខតំណែង លោកជំទាវ **ម៉ាណា ម៉ារីយ៉ា** ពីសមាសភាពប្រតិភូនៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ មានឋានៈស្មើ អនុរដ្ឋ-លេខាធិការ និងតែងតាំងនិងផ្តល់ឋានៈ លោកជំទាវ **អ៊ុន ស្រស់** ជាសមាសភាពប្រតិភូនៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៩៤៧៥

១-១១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/១១២៥/១៤៤៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ដល់មន្ត្រីរាជការ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងសមុច្ច័យឯកជន ៤រូប ៩៤៧៧

១-១១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/១១២៥/១៤៤៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ដល់ក្រឡាបញ្ជី នៃក្រសួងយុត្តិធម៌ ២រូប ៩៤៧៨

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

១៤-១០-២០២៥ -អនុក្រឹត្យលេខ ១៩៤ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៩៤៧៩

២០-១០-២០២៥ -អនុក្រឹត្យលេខ ១៩៥ អនក្រ.បក ស្តីពី ការផ្ទេរទ្រព្យសម្បត្តិរដ្ឋ ៩៤៨១

១៦-១០-២០២៥ -អនុក្រឹត្យលេខ ៨៧២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៤៨៣

### ២~បទបញ្ជា

២១-១០-២០២៥ -បទបញ្ជាលេខ ០២ បប ស្តីពី ការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា ៩៥០៣

## III~ការងារបណ្តាក្រសួង

### ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

១-៧-២០២៥ -ប្រកាសលេខ ៣៩៧ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ផាក ហេនប៉ែក (ខេមបូឌា) ឯ.ក បង្កើតរោងចក្រផលិតកាបូប និងគ្រឿងបន្ទាប់បន្សំកាបូបគ្រប់ប្រភេទ ៩៥០៥

១-៧-២០២៥ -ប្រកាសលេខ ៣៩៨ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហួយ ស៊ុន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ៩៥០៨

២-៧-២០២៥ -ប្រកាសលេខ ៤១១ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន នីឌិច ដាយ-ខាសធីង (ខេមបូឌា) ឯ.ក បង្កើតរោងចក្រផលិតគ្រឿងបង្គុំអេឡិកត្រូនិក និងគ្រឿងបង្គុំអគ្គិសនី ៩៥១១

២-៧-២០២៥ -ប្រកាសលេខ ៤១២ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្គាំហ្សែល អ៊ិនធើ-ណេសិនណល (ខេមបូឌា) ឯ.ក បង្កើតរោងចក្រផលិតម្ជុក និងកាបូប ៩៥១៤

# ព្រះរាជក្រម

នស/រកម/១១២៥/ ០៣៥

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើពិធីសារទីពីរ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ នាសម័យប្រជុំព្រឹទ្ធសភាលើកទី៤ នីតិកាលទី៥ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ការអនុម័តយល់ព្រមលើ

# ពិធីសារទីពីរ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់

**មាត្រា១ .-**

អនុម័តយល់ព្រមលើពិធីសារទីពីរ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ ដែលបានចុះហត្ថលេខានៅក្រុងសិម៉ារ៉ាងនៃសាធារណរដ្ឋឥណ្ឌូណេស៊ី នាថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ។

**មាត្រា៣ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ៣រោច ខែ កត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ២០២៥

ពរល.២៥១១.១៤៩៩

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម និម្មល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩៣៧ ស.ប្រ.ស.ច

## សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាពជូនលោកជំទាវ **ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានសម្រាប់កម្ពុជា ដើម្បីចុះហត្ថលេខាក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាលើពិធីសារដូចខាងក្រោមៈ

១- ពិធីសារទីមួយដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៃប្រទេសចិន

២- ពិធីសារទីពីរដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់។

ដើម្បីជាសក្ខីភាព **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោមលើសិទ្ធិប្រទាននេះ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

ព្រះរាជាណាចក្រកម្ពុជា
*Kingdom of Cambodia*

ជាតិ សាសនា ព្រះមហាក្សត្រ
*Nation Religion King*

រាជរដ្ឋាភិបាល
*Royal Government*

Nº 97 DFP

Phnom Penh, 30 November , 2023

# DELEGATION OF FULL POWERS

- Having seen the Constitution of the Kingdom of Cambodia;
- Having seen the Royal Decree NS/RKT/0823/1981 dated 22 August 2023 on the Nomination of the Royal Government of the Kingdom of Cambodia;
- Having seen the Royal Kram NS/RKM/0618/012 dated 28 June 2018 promulgating the Law on the Organization and Functioning of the Council of Ministers;
- Having seen the Royal Kram NS/RKM/0196/16 dated 24 January 1996 promulgating the Law on the Establishment of the Ministry of Commerce; and
- Referring to the request of the Minister of Commerce.

## THE ROYAL GOVERNMENT OF CAMBODIA

Delegates herewith Full Powers to Her Excellency **CHAM NIMUL**, Minister of Commerce and ASEAN Economic Minister for Cambodia, to sign, on behalf of the Royal Government of the Kingdom of Cambodia, the following Protocols:

1. First Protocol to Amend the ASEAN-Hong Kong, China Free Trade Agreement;
2. Second Protocol to Amend the Agreement Establishing the ASEAN-Australia-New Zealand Free Trade Area

In witness whereof, the undersigned, the Prime Minister of the Kingdom of Cambodia, with Full Powers duly entrusted to her, has signed the Delegation of Full Powers.

**Prime Minister**

**Samdech Moha Borvor Thipadei HUN MANET**

QR-Code

**សម្រាប់ទាញយកឯកសារៈ**

ពិធីសារទីពីរ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរី
អាស៊ាន អូស្ត្រាលី នូវែលសេឡង់ (ភាសាខ្មែរ)

ពិធីសារទីពីរ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរី
អាស៊ាន អូស្ត្រាលី នូវែលសេឡង់ (ភាសាអង់គ្លេស)

ព័ត៌មានបន្ថែមសូមទាក់ទងៈ

- លោក តែ រតនា (089 699 989)

# ព្រះរាជក្រម

នស/រកម/១១២៥/០៣៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីក្របខ័ណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញនីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ នាសម័យប្រជុំព្រឹទ្ធសភាលើកទី៤ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើ
# កិច្ចព្រមព្រៀងស្តីពីក្របខ័ណ្ឌបទប្បញ្ញត្តិសុវត្ថិភាព
# ម្ហូបអាហារអាស៊ាន

**មាត្រា១ .–**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពីក្របខ័ណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន ដែលបានចុះហត្ថលេខានៅក្រុងនន់ថះបុរីនៃព្រះរាជាណាចក្រថៃ នាថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២ .–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

**មាត្រា៣ .–**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ៣រោច ខែ កត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ២០២៥

ព្រហ្មមុនី

**នរោត្តម សីហមុនី**

ពរល. ២៥១១. ១៥០០

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម និម្មល**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៩៥ ស.ប្រក

## សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាពជូនលោកជំទាវ **ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង ជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានសម្រាប់កម្ពុជា ដើម្បីចុះហត្ថលេខាក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាលើ កិច្ចព្រមព្រៀងអាស៊ានស្តីពីក្របខណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារ។

ដើម្បីជាសក្ខីភាព **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយមានសិទ្ធិពេញលេញ តាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោមលើសិទ្ធិប្រទាននេះ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# កិច្ចព្រមព្រៀង
# ស្ដីពី
# ក្របខ័ណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន

រដ្ឋាភិបាលនៃព្រុយណេដារ៉ូស្សាឡាម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលជារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (**អាស៊ាន**) (តទៅនេះហៅកាត់រួមគ្នាថា «**បណ្ដារដ្ឋសមាជិក** » ឬ ហៅកាត់រដ្ឋនីមួយៗថា «**រដ្ឋសមាជិក**»)។

**ដោយពិចារណា** លើទស្សនវិស័យក្នុងការធានាសុវត្ថិភាពម្ហូបអាហារនៅក្នុងអាស៊ាន ដូចដែលមានក្នុងផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ និងផែនការលម្អិតសង្គម-វប្បធម៌ សហគមន៍អាស៊ានឆ្នាំ២០២៥ បានអនុម័តដោយថ្នាក់ដឹកនាំកំពូលរបស់អាស៊ានទាំងអស់ កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៥។

**ដោយទទួលស្គាល់ថា** កិច្ចសហប្រតិបត្តិការនិងសមាហរណកម្មរបស់អាស៊ាន រួមបញ្ចូលនូវបញ្ហាសុវត្ថិភាពម្ហូបអាហារពាក់ព័ន្ធនឹងវិស័យកសិកម្ម សេដ្ឋកិច្ច និងសុខាភិបាល និងសារៈសំខាន់ដែលមានអភិក្រមគ្រប់ជ្រុងជ្រោយចំពោះការធ្វើសមាហរណកម្ម និងពង្រីកនូវគំនិតផ្ដួចផ្ដើមដើម្បីអនុវត្តគោលនយោបាយសុវត្ថិភាពម្ហូបអាហារអាស៊ាន (តទៅនេះហៅកាត់ថា «**គ.ស.ម.អ.**»)។

**ដោយធ្វើការកត់សម្គាល់ថា គ.ស.ម.អ.** និងក្របខ័ណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន (តទៅនេះហៅកាត់ថា «**ក.ប.ស.ម.អ.**») បានអនុម័តនៅឆ្នាំ២០១៥ និងឆ្នាំ២០១៦ ជាបន្តបន្ទាប់ ដោយរដ្ឋមន្ត្រីអាស៊ាន ទទួលបន្ទុកវិស័យកសិកម្មនិងរុក្ខាប្រមាញ់ (តទៅនេះហៅកាត់ថា AMAF) រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន (តទៅនេះហៅកាត់ថា AEM) និងកិច្ចប្រជុំរដ្ឋមន្ត្រីសុខាភិបាលអាស៊ាន (តទៅនេះហៅកាត់ថា AHMM) និង

**ដោយមានបំណង** បង្កើតកិច្ចព្រមព្រៀងមួយដែលផ្ដល់ឱ្យមានអភិក្រមរួមនិងប្រទាក់ក្រឡាគ្នា ក្នុងការធានាថាសុវត្ថិភាពម្ហូបអាហារ ត្រូវបានអនុវត្តក្នុងខ្សែច្រវាក់ផលិតកម្មម្ហូបអាហារទាំងមូលនិងជំរុញលើការប្ដេជ្ញាចិត្តនានាដែលមានស្រាប់ដើម្បីផ្ដល់ជាចេនាសម្ព័ន្ធមួយដែលធ្វើឱ្យមានលំហូរម្ហូបអាហារមានសុវត្ថិភាពដោយសេរីនៅក្នុងតំបន់។

**បានព្រមព្រៀងគ្នា ដូចខាងក្រោម៖**

## មាត្រា១
## គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះ គឺដើម្បីបង្កើតនូវអភិក្រមរួមទូទៅនិងមានលក្ខណៈគ្រប់ជ្រុងជ្រោយ នៅក្នុងបណ្ដារដ្ឋសមាជិក ក្នុងគោលដៅសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

- ក- ធានាការពារសុខភាពអ្នកប្រើប្រាស់ និង
- ខ- សម្រួលឱ្យមានលំហូរនៃម្ហូបអាហារដែលមានសុវត្ថិភាពដោយសេរីនៅក្នុងអាស៊ាន តាមរយៈ៖
  - ១- ការពង្រឹងសុខដុមនីយកម្មនៃវិធានអនាម័យនិងភូតគាមអនាម័យ និងស្តង់ដាម្ហូបអាហារ
  - ២- ការកាត់បន្ថយរបាំងបច្ចេកទេស ចំពោះការធ្វើពាណិជ្ជកម្មម្ហូបអាហារនៅក្នុងតំបន់អាស៊ានឱ្យនៅកម្រិតអប្បបរមា និង
  - ៣- ការកាត់បន្ថយភាពមិនស៊ីសង្វាក់គ្នានៃប្រព័ន្ធត្រួតពិនិត្យម្ហូបអាហារនៅក្នុងបណ្ដារដ្ឋសមាជិក។

## មាត្រា២
## និយមន័យ

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ និយមន័យនៃវាក្យសព្ទត្រូវបានកំណត់ ដូចខាងក្រោម៖

ក- **អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់ស្ថាប័នរដ្ឋាភិបាលផ្លូវការដែលមានយុត្តាធិការ។

ខ- **ចំណីសត្វ** សំដៅដល់វត្ថុធាតុតែមួយឬច្រើនប្រភេទ ទោះបីជាកែច្នៃទាំងស្រុង ពាក់កណ្ដាលកែច្នៃ ឬមិនទាន់កែច្នៃ ត្រូវយកទៅចិញ្ចឹមសត្វដែលសម្រាប់យកទៅផលិតជាម្ហូបអាហារ។

គ- **ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលខុសត្រូវសម្រាប់ប្រតិបត្តិការអាជីវកម្ម នៅគ្រប់ដំណាក់កាលនៃខ្សែច្រវាក់ផលិតកម្មម្ហូបអាហារ។

ឃ- **សុវត្ថិភាពម្ហូបអាហារ** សំដៅដល់ការធានាថា ម្ហូបអាហារមិនបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ ស្របតាម បំណងនៃការប្រើ នៅពេលដែលម្ហូបអាហារនោះ ត្រូវបាន៖

១- រៀបចំ

២- ទទួលទាន ឬ

៣- រៀបចំនិងទទួលទាន

ង- **ពិធីសារ** សំដៅដល់ឯកសារ ដែលកំណត់អំពីកាតព្វកិច្ចនិងសិទ្ធិនៃបណ្ដារដ្ឋសមាជិក ដោយត្រូវគោរពតាមការអនុវត្ត វិធានសុវត្ថិភាពម្ហូបអាហារ រួមមាន ការរៀបចំរួមគ្នាដែលបានយល់ព្រមនិងចុះហត្ថលេខាដោយបណ្ដារដ្ឋសមាជិក។

ច- **ហានិភ័យ** សំដៅដល់មុខងារនៃលទ្ធភាពដែលអាចនាំឱ្យមានផលប៉ះពាល់ផ្នែកសុខភាពធ្ងន់ធ្ងរហើយភាពធ្ងន់ធ្ងរ នៃផលប៉ះពាល់នោះ អាស្រ័យមកពីភ្នាក់ងារបង្កគ្រោះនៅក្នុងម្ហូបអាហារ។

ឆ- **ការវិភាគហានិភ័យ** សំដៅដល់ដំណើរការដែលមាន៣(បី) ផ្នែក ដូចខាងក្រោម៖

១- ការសិក្សាវាយតម្លៃហានិភ័យ

២- ការគ្រប់គ្រងហានិភ័យ និង

៣- ការប្រាស្រ័យទំនាក់ទំនងហានិភ័យ

ជ- **ការសិក្សាវាយតម្លៃហានិភ័យ** សំដៅដល់ដំណើរការសិក្សាវាយតម្លៃផលប៉ះពាល់ដោយ ផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ ដែលត្រូវអនុវត្តតាមជំហាន ដូចខាងក្រោម៖

១- ការកំណត់អត្តសញ្ញាណនៃភ្នាក់ងារបង្កគ្រោះ

២- ការកំណត់ចរិតលក្ខណៈនៃភ្នាក់ងារបង្កគ្រោះ

៣- ការវាយតម្លៃអំពីផលទទួលរងដោយភ្នាក់ងារបង្កគ្រោះ និង

៤- ការកំណត់ចរិតលក្ខណៈរបស់ហានិភ័យ

ឈ- **ការប្រាស្រ័យទំនាក់ទំនងហានិភ័យ** សំដៅដល់ការផ្លាស់ប្ដូរព័ត៌មាននិងមតិយោបល់រវាងគ្នា តាមរយៈដំណើរការ នៃការវិភាគហានិភ័យដែលពាក់ព័ន្ធនឹងហានិភ័យ កត្តាផ្សេងៗទៀតដែលបង្កហានិភ័យពាក់ព័ន្ធនឹងហានិភ័យ និងការយល់ដឹងអំពីហានិភ័យ ក្នុងចំណោមអ្នកវាយតម្លៃហានិភ័យ អ្នកគ្រប់គ្រងហានិភ័យ អ្នកប្រើប្រាស់ ឧស្សាហកម្ម ក្រុមអ្នកស្រាវជ្រាវ និងភាគីពាក់ព័ន្ធផ្សេងៗទៀត ដោយរួមបញ្ចូលទាំងការពន្យល់អំពីការរកឃើញនៃការសិក្សា វាយតម្លៃហានិភ័យ និងមូលដ្ឋាននៃការសម្រេចចិត្តគ្រប់គ្រងហានិភ័យ។

ញ- **ការគ្រប់គ្រងហានិភ័យ** សំដៅដល់ដំណើរការនៃការថ្លឹងថ្លែងនូវជម្រើសគោលនយោបាយដែលមានលក្ខណៈខុសពី ការសិក្សាវាយតម្លៃហានិភ័យ។ ដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដែលពិចារណាលើការសិក្សា វាយតម្លៃហានិភ័យ និងកត្តាពាក់ព័ន្ធផ្សេងៗទៀត សម្រាប់ការការពារសុខភាពអ្នកប្រើប្រាស់ និងជំរុញការធ្វើពាណិជ្ជកម្ម ដោយយុត្តិធម៌ ហើយត្រូវជ្រើសរើសយកវិធានការត្រួតពិនិត្យ និងវិធានការបង្ការដែលសមស្រប ក្នុងករណីចាំបាច់។ និង

ដ- **ការអង្កេតដាន** សំដៅដល់លទ្ធភាពនៃការតាមដាននូវចលនាបម្លាស់ទីនៃម្ហូបអាហារនៅគ្រប់ដំណាក់កាលជាក់លាក់ ណាមួយនៃផលិតកម្ម ការកែច្នៃ និងការចែកចាយ។

## មាត្រា៣
## វិសាលភាព

១- កិច្ចព្រមព្រៀងនេះ កំណត់គោលការណ៍ លក្ខខណ្ឌតម្រូវ ដំណើរការ និងយន្តការសម្របសម្រួលសម្រាប់អនុវត្ត **គ.ស.ម.អ.** និងដោះស្រាយការត្រួតពិនិត្យសុវត្ថិភាពម្ហូបអាហារនៅគ្រប់ខ្សែច្រវាក់ផ្គត់ផ្គង់ម្ហូបអាហារ។

២- កិច្ចព្រមព្រៀងនេះ មិនអនុវត្តចំពោះបញ្ហាដែលពាក់ព័ន្ធនឹងគុណភាពម្ហូបអាហារ ម្ហូបអាហារសរីរាង្គ សុខុមាលភាពសត្វ និរន្តរភាព សន្តិសុខស្បៀង ការការពារបរិស្ថាន ឬការបម្រែបម្រួលអាកាសធាតុ ឬវត្ថុផ្សេងៗទៀតដែលមិនបង្កឱ្យម្ហូបអាហារមានបញ្ហា និងបង្កគ្រោះថ្នាក់ដល់សុខភាព ឬក៏មិនមានលក្ខណៈសមស្របសម្រាប់មនុស្សប្រើប្រាស់។

## មាត្រា៤
## គោលការណ៍

១- រដ្ឋសមាជិកនីមួយៗ ត្រូវកសាងនិងអនុវត្តនូវវិធានសុវត្ថិភាពម្ហូបអាហារ ពាក់ព័ន្ធនឹងសុខភាពអ្នកប្រើប្រាស់ និងសម្រួលលំហូរនៃម្ហូបអាហារដែលមានសុវត្ថិភាពដោយសេរីនៅក្នុងអាស៊ាន ដោយផ្អែកលើគោលការណ៍ទាំង១០ ដែលបានចែងក្នុង **គ.ស.ម.អ.**។

២- ស្ថាប័នអាស៊ានដែលមានសមត្ថកិច្ចទទួលបន្ទុកលើវិស័យកសិកម្ម សេដ្ឋកិច្ច និងសុខាភិបាល ត្រូវចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពនូវប្រព័ន្ធត្រួតពិនិត្យសុវត្ថិភាពម្ហូបអាហារ នៅក្នុងអាស៊ាន។

៣- កិច្ចព្រមព្រៀងនេះ ត្រូវការពារសុខភាពអ្នកប្រើប្រាស់ តាមរយៈការធ្វើបរិយាបន្ននៃលក្ខខណ្ឌតម្រូវក្នុងគោលបំណងបង្ការៈ
   ក- ម្ហូបអាហារគ្មានសុវត្ថិភាព និង
   ខ- ការក្លែងម្ហូបអាហារ ការអនុវត្តដោយក្លែងបន្លំ ឬការអនុវត្តដោយបំភាន់ដែលធ្វើឱ្យម្ហូបអាហារគ្មានសុវត្ថិភាព។

៤- រដ្ឋសមាជិកនីមួយៗ ត្រូវធានាថាវិធានសុវត្ថិភាពម្ហូបអាហារទាំងអស់ដែលអនុវត្តក្រោមកិច្ចព្រមព្រៀង នេះត្រូវផ្អែកលើមូលដ្ឋាននៃការវិភាគហានិភ័យសមស្របជាក់ស្តែង។ ការសិក្សាវិភាគហានិភ័យសុវត្ថិភាពម្ហូបអាហារទាំងនោះ ត្រូវផ្អែកលើភស្តុតាងវិទ្យាសាស្ត្រដែលមានស្រាប់ និងត្រូវធ្វើឡើងដោយមានលក្ខណៈឯករាជ្យ មានគោលបំណងច្បាស់លាស់ និងតម្លាភាព ស្របតាមគោលការណ៍ទី៣នៃ **គ.ស.ម.អ.** ស្តីពីដំណើរការនៃការវិភាគហានិភ័យដោយផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ និងមានលក្ខណៈឯករាជ្យ។ ហានិភ័យសុវត្ថិភាពម្ហូបអាហារ គួរត្រូវបានធ្វើប្រាស្រ័យទាក់ទងគ្នាជាមួយនឹងរដ្ឋសមាជិកផ្សេងទៀត ដើម្បីអនុវត្តវិធានការត្រួតពិនិត្យនៅក្នុងដែនដីរបស់ខ្លួន។

៥- ក្នុងកាលៈទេសៈជាក់លាក់ នៅពេលដែលមានការវាយតម្លៃលើព័ត៌មានដែលមានស្រាប់ និងនៅពេលដែលលទ្ធភាពនៃផលប៉ះពាល់ដល់សុខភាពត្រូវបានរកឃើញ ប៉ុន្តែភស្តុតាងផ្នែកវិទ្យាសាស្ត្រមិនទាន់ច្បាស់លាស់ រដ្ឋសមាជិកណាមួយអាចអនុវត្តវិធានការគ្រប់គ្រងហានិភ័យជាបណ្តោះអាសន្ន ដើម្បីធានាការពារសុខភាពអ្នកប្រើប្រាស់ ដោយរង់ចាំព័ត៌មានវិទ្យាសាស្ត្របន្ថែមទៀត សម្រាប់ការធ្វើវិភាគហានិភ័យឱ្យបានគ្រប់ជ្រុងជ្រោយ។

៦- វិធានការនានាដែលកំណត់ដោយរដ្ឋសមាជិកណាមួយ ដោយផ្អែកលើកថាខណ្ឌទី៥ ត្រូវសមាមាត្រនិងមិនរឹតត្បិតចំពោះការធ្វើពាណិជ្ជកម្ម ជាជាងតម្រូវការចាំបាច់ដើម្បីសម្រេចបាននូវកម្រិតនៃការការពារដែលមានស្រាប់។ វិធានការទាំងនោះ ត្រូវយកមកត្រួតពិនិត្យឡើងវិញ ក្នុងរយៈពេលដ៏សមស្របណាមួយដោយផ្អែកលើលក្ខណៈនៃហានិភ័យចំពោះជីវិតឬសុខភាពនិងប្រភេទនៃព័ត៌មានវិទ្យាសាស្ត្រដែលត្រូវការសម្រាប់បញ្ជាក់អំពីភាពមិនច្បាស់លាស់ផ្នែកវិទ្យាសាស្ត្រ និងដើម្បីធ្វើការវាយតម្លៃហានិភ័យគ្រប់ជ្រុងជ្រោយបន្ថែមទៀត។ រដ្ឋសមាជិកនោះ ត្រូវជូនដំណឹងជាបន្ទាន់ទៅបណ្តារដ្ឋសមាជិកដទៃទៀត ចំពោះវិធានការគ្រប់គ្រងហានិភ័យជាបណ្តោះអាសន្នដែលបានយកមកអនុវត្ត។

៧- រដ្ឋសមាជិកនីមួយៗ ត្រូវស្វែងរកសុខដុមនីយកម្មស្តង់ដា គោលការណ៍ណែនាំ លក្ខខណ្ឌតម្រូវ និងវិធានការសម្រាប់សុវត្ថិភាពម្ហូបអាហាររបស់ខ្លួន ដែលត្រូវបានកំណត់ដោយ គណៈកម្មាធិការកូដិចអាលីមេនថេរៀស (តទៅនេះហៅកាត់ថា CAC) លើកលែងតែមានការកំណត់ផ្សេងៗទៀត ដូចមានចែងក្នុងកិច្ចព្រមព្រៀងស្តីពីការអនុវត្តវិធានអនាម័យនិងភូតគាមអនាម័យ (តទៅនេះហៅកាត់ថា កិច្ចព្រមព្រៀង SPS)។

៨- លក្ខខណ្ឌតម្រូវនៃការនាំចេញនិងនាំចូលម្ហូបអាហារ ក្រោមកិច្ចព្រមព្រៀងនេះ ត្រូវមានសង្គតិភាពនឹងកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន កិច្ចព្រមព្រៀងស្តីពី SPS និងកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេស ចំពោះការធ្វើពាណិជ្ជកម្មនៃអង្គការពាណិជ្ជកម្មពិភពលោក។

៩- រដ្ឋសមាជិកនីមួយៗ ត្រូវខិតខំប្រឹងប្រែងចូលរួមឱ្យសកម្ម ក្នុងការបង្កើតស្តង់ដាម្ហូបអាហារអន្តរជាតិ គោលការណ៍ណែនាំ និងឯកសារអនុសាសន៍នានា ជាពិសេសក្នុងក្របខ័ណ្ឌនៃគណៈកម្មាធិការកូដិចអាលីមេនថេរៀស (CAC)។

១០- គំនិតផ្តួចផ្តើមនានារបស់អាស៊ានពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារ ដែលមានមុនពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន ត្រូវយកមកគិតពិចារណា ហើយការអនុវត្តនូវគំនិតផ្តួចផ្តើមទាំងនោះត្រូវសម្របសម្រួលឱ្យបានសមស្រប។

## មាត្រា៥
## បទប្បញ្ញត្តិទូទៅ

១- **រដ្ឋសមាជិកនីមួយៗ** ត្រូវបង្កើតឱ្យមានប្រព័ន្ធត្រួតពិនិត្យសុវត្ថិភាពម្ហូបអាហារ និងអនុវត្តប្រព័ន្ធនោះនៅគ្រប់ដំណាក់កាលនៃខ្សែច្រវាក់ផលិតកម្ម រួមទាំងចំណីសត្វ ក្នុងករណីដែលវាអាចមានផលប៉ះពាល់ដល់សុវត្ថិភាពម្ហូបអាហារ។

២- **លក្ខខណ្ឌតម្រូវទូទៅសម្រាប់សុវត្ថិភាពម្ហូបអាហារ**

រដ្ឋសមាជិកនីមួយៗ ត្រូវ៖

ក- ធានាថាវិធានសុវត្ថិភាពម្ហូបអាហារ ត្រូវបានធ្វើឡើងដើម្បីធានាថា ម្ហូបអាហារដែលចរាចរនៅលើទីផ្សារមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់របស់មនុស្ស។

ខ- ធានាថាវិធានសុវត្ថិភាពម្ហូបអាហារនីមួយៗ ត្រូវបានអនុវត្តចំពោះតែភាពចាំបាច់នៃការការពារសុខភាពអ្នកប្រើប្រាស់ ដោយផ្អែកលើគោលការណ៍វិទ្យាសាស្ត្រ និងមិនត្រូវប្រកាន់យកមកអនុវត្ត នៅពេលដែលមិនមានភស្តុតាងវិទ្យាសាស្ត្រច្បាស់លាស់ឡើយ។ ក្នុងករណីដែលភស្តុតាងវិទ្យាសាស្ត្រដែលពាក់ព័ន្ធមិនមានគ្រប់គ្រាន់ រដ្ឋសមាជិកនោះ ត្រូវដាក់ចេញនូវវិធានសុវត្ថិភាពម្ហូបអាហារជាបណ្តោះអាសន្ន ដោយផ្អែកលើព័ត៌មានដែលមាន ដោយរាប់បញ្ចូលទាំងវិធានដែលទទួលបានពីអង្គការអន្តរជាតិពាក់ព័ន្ធ ក៏ដូចជាវិធានអនាម័យនិងភូតគាមអនាម័យដែលបានអនុវត្តដោយរដ្ឋសមាជិកដទៃទៀតផងដែរ។ ក្នុងកាលៈទេសៈបែបនេះ រដ្ឋសមាជិកនោះ ត្រូវស្វែងរកព័ត៌មានចាំបាច់បន្ថែមទៀតដើម្បីធ្វើការវិភាគហានិភ័យ ដោយមានគោលបំណងច្បាស់លាស់បន្ថែមទៀត និងពិនិត្យឡើងវិញនូវវិធានសុវត្ថិភាពម្ហូបអាហារ ក្នុងពេលសមស្របណាមួយជាក់លាក់។

គ- ធានាថារាល់លក្ខខណ្ឌតម្រូវនានានៃច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារត្រូវបានអនុវត្តដោយប្រតិបត្តិករអាជីវកម្មម្ហូបអាហារនៅគ្រប់ដំណាក់កាលនៃខ្សែច្រវាក់ផលិតកម្ម ការកែច្នៃ និងការចែកចាយ។

ឃ- រក្សាប្រព័ន្ធត្រួតពិនិត្យផ្លូវការនិងសកម្មភាពផ្សេងៗទៀត សមស្របតាមកាលៈទេសៈនោះ រួមមាន ការប្រាស្រ័យទំនាក់ទំនងសាធារណៈ ស្តីពីសកម្មភាពនៃការឃ្លាំពិនិត្យម្ហូបអាហារ ដែលគ្របដណ្តប់លើគ្រប់ដំណាក់កាលនៃខ្សែច្រវាក់ផលិតកម្ម ការកែច្នៃ និងការចែកចាយ។

ង- ដាក់ចេញនូវបទប្បញ្ញត្តិស្តីពីវិធានការនិងទណ្ឌកម្មចំពោះការបំពានច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារ។ វិធានការនិងទណ្ឌកម្មដែលបានដាក់នោះ ត្រូវមានប្រសិទ្ធភាព សមាមាត្រ និងជឿទុកចិត្តបាន។

ច- ត្រូវពិចារណាជាពិសេស ចំពោះសហគ្រាសធុនតូចនិងមធ្យម ដើម្បីអាចឱ្យពួកគេអភិវឌ្ឍប្រព័ន្ធសុវត្ថិភាពម្ហូបអាហាររបស់ខ្លួន តាមស្ថានភាពជាក់ស្តែង ប៉ុន្តែមិនត្រូវមានការសម្របសម្រួលចំពោះសុវត្ថិភាពម្ហូបអាហារឡើយ។ និង

ឆ- ធានាថាម្ហូបអាហារដែលនាំចេញឬនាំចេញបន្តទៅកាន់ទីផ្សារនៃរដ្ឋសមាជិកផ្សេងទៀត ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវនានានៃកិច្ចព្រមព្រៀងនេះ។

៣- **ការដាក់ស្លាកសញ្ញា**

រដ្ឋសមាជិកនីមួយៗ ត្រូវធានាថាច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួនពាក់ព័ន្ធនឹងការដាក់ស្លាកសញ្ញា ត្រូវមានចែងនូវបញ្ញត្តិហាមឃាត់ចំពោះព័ត៌មានដែលមានលក្ខណៈបំភាន់និងឆបោកអំពីសុវត្ថិភាពម្ហូបអាហារ ដែលអាចធ្វើទៅបានតាមគ្រប់មធ្យោបាយ។



ᖰ 118

**៤- ការអង្កេតដាន**

ក្នុងគោលបំណងនៃអនុលោមភាពសុវត្ថិភាពម្ហូបអាហារ និងដើម្បីអនុញ្ញាតឱ្យមានការប្រមូលម្ហូបអាហារដែលគ្មានសុវត្ថិភាពត្រឡប់មកវិញ រដ្ឋសមាជិកនីមួយៗ ត្រូវធានាថាច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន តម្រូវឱ្យប្រតិបត្តិករអាជីវកម្មម្ហូបអាហាររក្សានូវប្រព័ន្ធអង្កេតដាននៃម្ហូបអាហារនៅគ្រប់ដំណាក់កាលនៃខ្សែច្រវាក់ផលិតកម្ម ការកែច្នៃ និងការចែកចាយ។

**៥- លក្ខខណ្ឌតម្រូវទូទៅសម្រាប់សុវត្ថិភាពចំណីសត្វ**

រដ្ឋសមាជិកនីមួយៗ ត្រូវធានាថា វិធានការដែលបានដាក់ឱ្យអនុវត្តត្រូវប្រាកដថាចំណីសត្វមិនត្រូវយកទៅឱ្យសត្វដែលផលិតជាម្ហូបអាហារ ប្រសិនបើចំណីសត្វនោះមានផលប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ឬធ្វើឱ្យម្ហូបអាហារដែលកើតចេញសត្វចិញ្ចឹមជាម្ហូបអាហារមិនមានសុវត្ថិភាព សម្រាប់ការប្រើប្រាស់របស់មនុស្ស។

**៦- ការប្រកាសអាសន្នជាបន្ទាន់ចំពោះសុវត្ថិភាពម្ហូបអាហារ**

ក- នៅពេលដែលមានមូលដ្ឋានសមស្របសង្ស័យថា ម្ហូបអាហារឬចំណីសត្វមានហានិភ័យប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ រដ្ឋសមាជិកនីមួយៗ ត្រូវចាត់វិធានការសមស្រប ដើម្បីជូនដំណឹងជាសាធារណៈដោយផ្អែកលើលក្ខណៈ ភាពធ្ងន់ធ្ងរ និងទំហំនៃហានិភ័យនោះ។ ព័ត៌មានបែបនេះ ត្រូវចែករំលែកជាមួយរដ្ឋសមាជិកដទៃទៀត។ ការចូលរួមនៅក្នុងប្រព័ន្ធផ្តល់ព័ត៌មានទាន់ហេតុការណ៍របស់អាស៊ានស្តីពីម្ហូបអាហារនិងចំណីសត្វ អាចនាំឱ្យមានការផ្លាស់ប្តូរព័ត៌មានស្តីពីសុវត្ថិភាពម្ហូបអាហាររវាងរដ្ឋសមាជិក បានទាន់ពេលវេលា។

ខ- រដ្ឋសមាជិកនីមួយៗ ត្រូវកសាងនិងអនុវត្តវិធានការសមស្រប ដើម្បីឆ្លើយតបទៅនឹងការប្រកាសអាសន្នជាបន្ទាន់ចំពោះសុវត្ថិភាពម្ហូបអាហារដែលកើតនៅក្នុងដែនដីរបស់ខ្លួន។

## មាត្រា៦
## ការទទួលស្គាល់លទ្ធផលនៃការធ្វើអធិការកិច្ច វិញ្ញាបនបត្រកម្ម និងវិធានអនាម័យនិងភូតគាមអនាម័យ

រដ្ឋសមាជិកនីមួយៗ ត្រូវទទួលស្គាល់នូវលទ្ធផលនៃការធ្វើអធិការកិច្ច វិញ្ញាបនបត្រកម្ម និងវិធានអនាម័យនិងភូតគាមអនាម័យរបស់រដ្ឋសមាជិកដទៃទៀត ដូចបានចែងក្នុងពិធីសារនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា៧
## គណៈកម្មាធិការសម្របសម្រួលសុវត្ថិភាពម្ហូបអាហារអាស៊ាន

១- គណៈកម្មាធិការសម្របសម្រួលសុវត្ថិភាពម្ហូបអាហារអាស៊ាន(តទៅនេះហៅកាត់ថា **គ.ស.ស.ម.អ.**) ត្រូវបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងនេះ។

២- **គ.ស.ស.ម.អ.** ត្រូវមានមុខងារ ដូចខាងក្រោម៖

ក- រៀបចំផែនការ គ្រប់គ្រង និងពិនិត្យឡើងវិញ ចំពោះការអនុវត្តកិច្ចព្រមព្រៀងនេះ។

ខ- សម្របសម្រួលជាមួយស្ថាប័នអាស៊ានពាក់ព័ន្ធក្រោម AMAF, AEM និង AHMM សម្រាប់ការកសាងពិធីសារស្របតាមមាត្រា១០ (ពិធីសារសម្រាប់កិច្ចព្រមព្រៀង) និងការអនុវត្តគំនិតផ្តួចផ្តើមអាស៊ានពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារ។

គ- គាំទ្រសំណើនៃពិធីសារ កំណត់អត្តសញ្ញាណស្ថាប័នអាស៊ានពាក់ព័ន្ធ ដើម្បីបង្កើតពិធីសារនិងផ្តល់ការគាំទ្រលើពិធីសារមុននឹងដាក់ជូនកិច្ចប្រជុំឧត្តមមន្ត្រីនៃរដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកវិស័យកសិកម្មនិងរុក្ខាប្រមាញ់ (តទៅនេះហៅកាត់ថា «SOM-AMAF») ឬកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ច (តទៅនេះហៅកាត់ថា «SEOM») ឬកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីការអភិវឌ្ឍវិស័យសុខាភិបាល (តទៅនេះហៅកាត់ថា «SOMHD») ដើម្បីស្នើសុំការអនុម័ត។ និង

ឃ- រាយការណ៍ជាប្រចាំអំពីវឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងនេះជូន SOM-AMAF, SEOM និង SOMHD។

## មាត្រា៨
## អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុវត្ថិភាពម្ហូបអាហារ

១- រដ្ឋសមាជិកនីមួយៗ ត្រូវកំណត់អត្តសញ្ញាណអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុវត្ថិភាពម្ហូបអាហាររបស់ខ្លួន និងត្រូវជូនដំណឹងទៅលេខាធិការដ្ឋានអាស៊ាន តាមស្ថានភាពជាក់ស្តែង។

២- រដ្ឋសមាជិកណាមួយដែលមានអាជ្ញាធរមានសមត្ថកិច្ចច្រើនត្រូវផ្ញើបញ្ជីឈ្មោះនៃអាជ្ញាធរមានសមត្ថកិច្ចទាំងអស់នោះ និងបញ្ជាក់អំពីតួនាទីនិងទំនួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចនីមួយៗឱ្យបានជាក់លាក់ដូចបានកំណត់ក្នុងវិសាលភាពនៃកិច្ចព្រមព្រៀងនេះ។ រដ្ឋសមាជិកដែលមានអាជ្ញាធរមានសមត្ថកិច្ចច្រើនទទួលបន្ទុកសុវត្ថិភាពម្ហូបអាហារ ត្រូវធានាថាអាជ្ញាធរមានសមត្ថកិច្ចទាំងនោះ ប្រតិបត្តិការដោយស៊ីសង្វាក់គ្នា មិនជាន់ភារកិច្ច ឬមិនមានភាពចន្លោះប្រហោង។

៣- ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកសុវត្ថិភាពម្ហូបអាហារនៃរដ្ឋសមាជិកនីមួយៗ ត្រូវមានលទ្ធភាពអនុវត្តនិងចាត់វិធានការអនុលោមទៅតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន។

## មាត្រា៩
## ចំណុចទំនាក់ទំនង

រដ្ឋសមាជិកនីមួយៗ ត្រូវចាត់តាំងចំណុចទំនាក់ទំនងមួយ សម្រាប់ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការក្រោមកិច្ចព្រមព្រៀងនេះឱ្យមានប្រសិទ្ធភាព និងត្រូវជូនដំណឹងទៅលេខាធិការដ្ឋានអាស៊ាន អំពីចំណុចទំនាក់ទំនងរបស់ខ្លួន។ លេខាធិការដ្ឋានអាស៊ាន ត្រូវបង្កើត ធ្វើបច្ចុប្បន្នភាព និងរក្សាបញ្ជីនៃចំណុចទំនាក់ទំនងទាំងនោះ សម្រាប់រដ្ឋសមាជិកដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះ។

## មាត្រា១០
## ពិធីសារសម្រាប់កិច្ចព្រមព្រៀងនេះ

១- ផែនការសម្រាប់បញ្ចប់ចំនួននៃពិធីសារដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះត្រូវបង្កើតឡើងនិងធ្វើបច្ចុប្បន្នភាព តាមពេលវេលាដោយ **គ.ស.ស.ម.អ**.។

២- សំណើកសាងពិធីសារ អាចផ្តើមឡើងពី **គ.ស.ស.ម.អ**. ឬ SOM-AMAF, SEOM ឬ SOMHD។ ដោយមានការពិគ្រោះយោបល់និងការឯកភាពពី SOM-AMAF, SEOM ឬ SOMHD រៀងៗខ្លួន **គ.ស.ស.ម.អ**. ត្រូវកំណត់ពិធីសារដែលត្រូវកសាងនិងកំណត់ស្ថាប័នអាស៊ានដែលត្រូវទទួលបន្ទុកសម្រាប់ការកសាងពិធីសារនោះ។

៣- ការកសាងពិធីសារ ត្រូវធ្វើឡើងដោយស្ថាប័នអាស៊ានដែលត្រូវបានកំណត់ដោយផ្អែកតាមកថាខណ្ឌទី២ ខាងលើ។ ពិធីសារនោះ ត្រូវបានគាំទ្រដោយ **គ.ស.ស.ម.អ**. ហើយត្រូវស្នើឡើងតាមលំដាប់លំដោយទៅ SOM-AMAF, SEOM ឬ SOMHD ដើម្បីទទួលបានការអនុម័ត។

៤- ពិធីសារទាំងនោះ ត្រូវបានបង្កើតជាផ្នែកសំខាន់នៃកិច្ចព្រមព្រៀងនេះ ដោយផ្អែកលើការចូលជាធរមាននៃពិធីសារនោះ។

៥- ដើម្បីអនុញ្ញាតឱ្យមានភាពបត់បែនចាំបាច់និងអភិក្រមមិនស៊ីសង្វាក់គ្នា ដោយបណ្តារដ្ឋសមាជិក ពិធីសារនីមួយៗ អាចដាក់បញ្ចូលបញ្ញត្តិសមស្របនានាពាក់ព័ន្ធនឹងលក្ខខណ្ឌនិងពេលវេលាដែលត្រូវអនុវត្ត ដោយបណ្តារដ្ឋសមាជិក។

## មាត្រា១១
## ការពង្រឹងសមត្ថភាពនិងកិច្ចសហប្រតិបត្តិការ

១- រដ្ឋសមាជិកនីមួយៗ អាចកំណត់កម្មវិធីកសាងសមត្ថភាពដែលចាំបាច់ដើម្បីពង្រឹងសមត្ថភាព ក្នុងគោលបំណងធានាឱ្យមានលក្ខខណ្ឌត្រួតពិនិត្យសុវត្ថិភាពម្ហូបអាហាររបស់ខ្លួន ដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ។ រដ្ឋសមាជិកនីមួយៗ អាចស្នើសុំ **គ.ស.ស.ម.អ**. ធ្វើការសម្របសម្រួលជាមួយរដ្ឋសមាជិកដទៃទៀត ដើម្បីកសាងកម្មវិធីពង្រឹងសមត្ថភាព។

២- បណ្ដារដ្ឋសមាជិក ត្រូវបានលើកទឹកចិត្តដើម្បីផ្ដល់កិច្ចសហប្រតិបត្តិការក្នុងការអនុវត្តកម្មវិធីកសាងសមត្ថភាព ស្របតាមលក្ខខណ្ឌដែលបានព្រមព្រៀងគ្នា។

**មាត្រា១២**
**តម្លាភាព**

១- រដ្ឋសមាជិកនីមួយៗ ត្រូវធានាថាច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួនពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារ ត្រូវបង្កភាពងាយស្រួលឱ្យបណ្ដារដ្ឋសមាជិកដទៃទៀតអាចរកបាន។

២- រដ្ឋសមាជិកនីមួយៗ ត្រូវធានាថាការកសាងច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួនពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារ ត្រូវធ្វើឡើងដោយមានលក្ខណៈតម្លាភាព។

**មាត្រា១៣**
**ការរក្សាការសម្ងាត់**

១- រដ្ឋសមាជិកនីមួយៗ ត្រូវរក្សាការសម្ងាត់នៃព័ត៌មានដែលត្រូវបានផ្លាស់ប្ដូរក្រោមកិច្ចព្រមព្រៀងនេះ ក្នុងកម្រិត ដែលអនុញ្ញាតដោយច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់ខ្លួន។ ព័ត៌មានសម្ងាត់ណាមួយអាចត្រូវបានបង្ហាញ លុះត្រាតែទទួលបានការអនុញ្ញាតពីរដ្ឋសមាជិកដែលបានផ្ដល់ព័ត៌មាននោះ។

២- បណ្ដារដ្ឋសមាជិក ត្រូវចាត់វិធានការបង្ការដែលចាំបាច់ ដើម្បីការពារព័ត៌មានដែលបានផ្លាស់ប្ដូរ ក្រោមកិច្ចព្រមព្រៀងនេះពីការបង្ហាញនូវព័ត៌មានទាំងឡាយណាដែលពុំមានការអនុញ្ញាត។

**មាត្រា១៤**
**ការដោះស្រាយវិវាទ**

ពិធីសារអាស៊ានស្ដីពីការលើកកម្ពស់យន្តការដោះស្រាយវិវាទ ដែលបានចុះហត្ថលេខា នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ នៅទីក្រុងវៀងចន្ទន៍នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ឬពិធីសារក្រោយៗទៀតរបស់ពិធីសារនេះ ត្រូវអនុវត្តចំពោះការដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្ត ការបកស្រាយ ឬការអនុវត្តនៃកិច្ចព្រមព្រៀងនេះ។

**មាត្រា១៥**
**វិសោធនកម្ម**

១- កិច្ចព្រមព្រៀងនេះ អាចធ្វើវិសោធនកម្មជាលាយលក្ខណ៍អក្សរ ដោយមានការយល់ព្រមពីបណ្ដារដ្ឋសមាជិក។

២- ការធ្វើវិសោធនកម្មណាមួយ មិនត្រូវប៉ះពាល់ដល់សិទ្ធិនិងកាតព្វកិច្ចនៃរដ្ឋសមាជិកដែលកើតចេញពី ឬដោយផ្អែកលើកិច្ចព្រមព្រៀងនេះ មុនពេលនិងរហូតដល់កាលបរិច្ឆេទនៃការធ្វើវិសោធនកម្មនោះ។

**មាត្រា១៦**
**សិទ្ធិនិងកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀង**
**ឬអនុសញ្ញាអន្តរជាតិដែលមានជាធរមាន**

កិច្ចព្រមព្រៀងនេះឬសកម្មភាពណាមួយដែលកើតចេញពីការអនុវត្តកិច្ចព្រមព្រៀងនេះ មិនត្រូវប៉ះពាល់ដល់សិទ្ធិនិងកាតព្វកិច្ចនៃរដ្ឋសមាជិកណាមួយដែលស្ថិតនៅក្រោមអនុសញ្ញាឬកិច្ចព្រមព្រៀងអន្តរជាតិជាធរមាន ដែលរដ្ឋសមាជិកនោះជាភាគីហត្ថលេខីឡើយ។

**មាត្រា១៧**
**ការតម្កល់ទុក**

កិច្ចព្រមព្រៀងនេះ ត្រូវបានតម្កល់ទុកជាមួយអគ្គលេខាធិការអាស៊ាន ដែលជាអ្នកត្រូវផ្ដល់ជូនភ្លាមៗនូវច្បាប់ចម្លងដែលបានបញ្ជាក់ ទៅកាន់រដ្ឋសមាជិកនីមួយៗ។

**មាត្រា១៩**

**អធិរាជប្បញ្ញត្តិ**

១- កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានចាប់ពីកាលបរិច្ឆេទនៃការតម្កល់លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការអនុម័ត ឬការយល់ព្រម ដោយរដ្ឋសមាជិកទាំង១០ ជាមួយនឹងអគ្គលេខាធិការអាស៊ាន។

២- គ្មានការរក្សាសិទ្ធិណាមួយ ត្រូវធ្វើឡើងចំពោះកិច្ចព្រមព្រៀងនេះ។

**ជាសក្ខីភាព** ហត្ថលេខីដែលត្រូវបានផ្តល់សិទ្ធិដោយរដ្ឋាភិបាលរបស់ខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

**បានធ្វើ** នៅក្រុងនន់ថៈបុរី នៃព្រះរាជាណាចក្រថៃ ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ចំនួនមួយច្បាប់ដើមជាភាសាអង់គ្លេស។

**តំណាងរដ្ឋាភិបាលនៃប្រទេសព្រុយណេដារ៉ូស្សាឡាម**

[ហត្ថលេខា]

DATO Dr. AMIN LIEW ABDULLAH

រដ្ឋមន្ត្រីប្រចាំទីស្តីការនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុនិងសេដ្ឋកិច្ច ll

**តំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**

[ហត្ថលេខា]

**ចម និម្មល**

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី**

[ហត្ថលេខា]

ZULKIFLI HASAN

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

[ហត្ថលេខា]

MALAITHONG KOMMASITH

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងពាណិជ្ជកម្ម



P 18

**តំណាងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី**

[ហត្ថលេខា]

TENGKU DATUK SERI UTAMA ZAFRUL TENGKU ABDUL AZIZ

រដ្ឋមន្ត្រីទទួលបន្ទុកការវិនិយោគ ពាណិជ្ជកម្ម និងឧស្សាហកម្ម

**តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា**

[ហត្ថលេខា]

KAN ZAW

រដ្ឋមន្ត្រីសហជីពទទួលបន្ទុក ការវិនិយោគ និងទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ

**តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន**

[ហត្ថលេខា]

ALFREDO E. PASCUAL

លេខាធិការពាណិជ្ជកម្មនិងឧស្សាហកម្ម

**តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី**

[ហត្ថលេខា]

GAN KIM YONG

រដ្ឋមន្ត្រីពាណិជ្ជកម្មនិងឧស្សាហកម្ម

**សម្រាប់តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ**

[ហត្ថលេខា]

PHUMTHAM WECHAYACHAI

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សម្រាប់តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម**

[ហត្ថលេខា]

NGUYEN HONG DIEN

រដ្ឋមន្ត្រីឧស្សាហកម្មនិងពាណិជ្ជកម្ម

ព្រះរាជាណាចក្រកម្ពុជា
*Kingdom of Cambodia*

ជាតិ សាសនា ព្រះមហាក្សត្រ
*Nation Religion King*

រាជរដ្ឋាភិបាល
*Royal Government*

Nº 95 DFP

Phnom Penh, 30 November , 2023

## DELEGATION OF FULL POWERS

- Having seen the Constitution of the Kingdom of Cambodia;
- Having seen the Royal Decree NS/RKT/0823/1981 dated 22 August 2023 on the Nomination of the Royal Government of the Kingdom of Cambodia;
- Having seen the Royal Kram NS/RKM/0618/012 dated 28 June 2018 promulgating the Law on the Organization and Functioning of the Council of Ministers;
- Having seen the Royal Kram NS/RKM/0196/16 dated 24 January 1996 promulgating the Law on the Establishment of the Ministry of Commerce; and
- Referring to the request of the Minister of Commerce.

## THE ROYAL GOVERNMENT OF CAMBODIA

Delegates herewith Full Powers to Her Excellency **CHAM NIMUL**, Minister of Commerce and ASEAN Economic Minister for Cambodia, to sign, on behalf of the Royal Government of the Kingdom of Cambodia, the ASEAN Food Safety Regulatory Framework Agreement.

In witness whereof, the undersigned, the Prime Minister of the Kingdom of Cambodia, with Full Powers duly entrusted to her, has signed the Delegation of Full Powers.

**Prime Minister**

**Samdech Moha Borvor Thipadei HUN MANET**

asean

## ASEAN FOOD SAFETY REGULATORY FRAMEWORK AGREEMENT

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Republic of the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand, and the Socialist Republic of Viet Nam, Member States of the Association of Southeast Asian Nations (ASEAN) (hereinafter collectively referred to as "Member States" or singularly as "Member State");

**CONSIDERING** the vision to ensure food safety in ASEAN as included in the ASEAN Economic Community Blueprint 2025 and the ASEAN Socio-Cultural Community Blueprint 2025, adopted by the ASEAN Leaders on 22 November 2015;

**RECOGNISING** that ASEAN cooperation and integration include the area of food safety that cuts across agriculture, economic, and health sectors and the importance of having a comprehensive approach to integrating and expanding initiatives to implement the ASEAN Food Safety Policy (hereinafter referred to as "AFSP");

**NOTING** the AFSP and the ASEAN Food Safety Regulatory Framework (hereinafter referred to as "AFSRF") adopted in 2015 and 2016 respectively by the ASEAN Ministers on Agriculture and Forestry (hereinafter referred to as "AMAF"), ASEAN Economic Ministers (hereinafter referred to as "AEM"), and ASEAN Health Ministers Meeting (hereinafter referred to as "AHMM"); and

**DESIRING** to establish an agreement which provides for a coherent and integrated approach to ensure that food safety

CERTIFIED COPY
asean
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

is implemented across the food chain and which builds upon the existing commitments in order to provide a structure to realise the free flow of safe food in the region,

**HAVE AGREED AS FOLLOWS:**

## Article 1
## Objective

The objective of this Agreement is to establish a comprehensive and integrated overall approach to food safety in Member States to achieve the following:

(a) ensure protection of consumers' health; and

(b) facilitate free flow of safe food within ASEAN by:

(i) enhancing the harmonisation of sanitary and phytosanitary measures and standards for food;

(ii) minimising technical barriers to intra-ASEAN trade in food; and

(iii) reducing discrepancies of national food control systems among Member States.

## Article 2
## Definitions

For the purposes of this Agreement, the following definitions shall apply:

(a) **Competent Authority** means the official government agency having jurisdiction;

(b) **feed** means any single or multiple materials, whether processed, semi-processed, or raw, which are



CERTIFIED COPY asean DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

intended to be fed directly to food-producing animals;

(c) **food business operator** means a natural or juridical person responsible for operating business at any step in the food chain;

(d) **food safety** means providing assurance that food, according to its intended use, will not cause harm to the consumer when it is:

(i) prepared;

(ii) eaten; or

(iii) prepared and eaten;

(e) **Protocol** means a document defining obligations and rights of the Member States with respect to the implementation of food safety measures, including associated arrangements, agreed upon and signed by the Member States;

(f) **risk** means a function of the probability of an adverse health effect and the severity of that effect, consequential to a hazard in food;

(g) **risk analysis** means a process consisting of three components:

(i) risk assessment;

(ii) risk management; and

(iii) risk communication;

(h) **risk assessment** means a scientifically-based process consisting of the following steps:

(i) hazard identification;



CERTIFIED COPY asean DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

(ii) hazard characterisation;

(iii) exposure assessment; and

(iv) risk characterisation;

(i) **risk communication** means the interactive exchange of information and opinions throughout the risk analysis process concerning risk, risk-related factors, and risk perceptions, among risk assessors, risk managers, consumers, industry, the academic community, and other interested parties, including the explanation of risk assessment findings and the basis of risk management decisions;

(j) **risk management** means the process, distinct from risk assessment, of weighing policy alternatives, in consultation with all interested parties, considering risk assessment and other factors relevant for the health protection of consumers and promotion of fair trade practices, and, if needed, selecting appropriate prevention and control options; and

(k) **traceability** means the ability to follow the movement of a food through specified stages of production, processing, and distribution.

## Article 3
## Scope

1. This Agreement provides principles, requirements, processes, and a coordinating mechanism for the implementation of the AFSP and addresses food safety control along the food supply chain.

2. Matters concerning food quality, organic food, animal welfare, sustainability, food security, environmental



CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

protection, or climate change, *inter alia*, which do not cause food to be injurious to health or unfit for human consumption, fall outside of the scope of this Agreement.

## Article 4
## Principles

1. Each Member State shall develop and apply food safety measures relating to the protection of consumers' health and to facilitate the free flow of safe food within ASEAN based on the 10 Principles of AFSP.

2. ASEAN bodies having purview over agriculture, economic, and health sectors shall engage effectively to implement a coherent food safety control system in ASEAN.

3. This Agreement shall protect consumers' health through the inclusion of requirements that are aimed at the prevention of:

   (a) unsafe food; and

   (b) adulteration of food, fraudulent practice, or deceptive practice, that pose a threat to the safety of food.

4. Each Member State shall ensure that all food safety measures implemented under this Agreement are based on risk analysis, as appropriate. Such food safety risk assessment shall be based on the available scientific evidence and undertaken in an independent, objective, and transparent manner, and in accordance with Principle 3: Science-based, Independent Risk Assessment Process of the AFSP. The food safety risks should be communicated to other Member States to implement control measures within each territory.



CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

5. In specific circumstances where, following an assessment of available information, and where the possibility of harmful effects on health is identified but scientific uncertainty persists, a Member State may implement provisional risk management measures necessary to ensure the continued protection of consumers' health, pending further scientific information for a more comprehensive risk assessment.

6. Measures adopted by a Member State on the basis of paragraph 5 shall be proportionate and no more restrictive to trade than is required to achieve the existing level of protection. The measures shall be reviewed within a reasonable period of time, depending on the nature of the risk to life or health identified and the type of scientific information needed to clarify the scientific uncertainty and to conduct a more comprehensive risk assessment. That Member State shall immediately notify other Member States of the provisional risk management measures adopted.

7. Each Member State shall seek to harmonise its standards, guidelines, requirements, and measures for food safety with those established by the Codex Alimentarius Commission (hereinafter referred to as the "CAC"), except as otherwise provided in the Agreement on the Application of Sanitary and Phytosanitary Measures (hereinafter referred to as the "SPS Agreement").

8. Food import and export requirements under this Agreement shall be consistent with the ASEAN Trade in Goods Agreement, the SPS Agreement, and the Agreement on Technical Barriers to Trade of the World Trade Organization.

9. Each Member State shall endeavour to actively participate in setting up international food standards,



CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

guidelines, and recommendations, in particular those of the CAC.

10. ASEAN initiatives relating to food safety in existence prior to the entry into force of this Agreement shall be taken into consideration and their implementation shall be appropriately coordinated.

## Article 5
## General Provisions

1. Each Member State shall put in place a food safety control system and implement such a system along the food chain, including for feed, in cases where it may have an impact on food safety.

2. **General Requirements for Food Safety**

   Each Member State shall:

   (a) ensure that food safety measures are in place to ensure that food to be placed on the market is safe for human consumption;

   (b) ensure that any food safety measure is applied only to the extent necessary to protect consumers' health, is based on scientific principles, and is not maintained without sufficient scientific evidence. In cases where relevant scientific evidence is insufficient, a Member State may provisionally adopt food safety measures on the basis of available pertinent information, including from the relevant international organisations as well as from sanitary or phytosanitary measures applied by other Member States. In such circumstances, that Member State shall seek to obtain the additional information necessary for a more objective assessment of risk



CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

and review the food safety measures accordingly within a reasonable period of time;

(c) ensure that the relevant requirements of its laws and regulations related to food safety are fulfilled by food business operators at all stages of production, processing, and distribution;

(d) maintain a system of official controls and other activities as appropriate to the circumstances, including public communication on food monitoring activities covering all stages of production, processing, and distribution;

(e) prescribe the rules on measures and penalties applicable to infringements of its laws and regulations related to food safety. The measures and penalties provided for shall be effective, proportionate, and dissuasive;

(f) give special consideration, without compromising food safety, to small and medium-sized enterprises to enable them to upgrade their food safety assurance systems that take into account their conditions; and

(g) ensure that food exported or re-exported to the market of any other Member State complies with the relevant requirements of this Agreement.

3. **Labelling**

Each Member State shall ensure that its laws and regulations related to food labelling incorporate a provision that prohibits misleading and deceiving information to be made available about food safety through any medium.



CERTIFIED COPY DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT asean

4. **Traceability**

